**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:២១៩
ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥
**<u>សាលដីកា</u>**
លេខ:៨៧
ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ............ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............... ជាចៅក្រម
៣-លោក ................ជាចៅក្រម
៤-លោក ............ ជាចៅក្រមរបាយការណ៍
៥-លោក ............... ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**
-លោក ................

**<u>តំណាងមហាអយ្យការ</u>**
-លោក .............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៥៨(គ) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៦៣ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះររ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៤៥ឆ្នាំ ជាតិខ្មែរ របរកសុីធ្វើស្រែ មានទីលំនៅភូមិអូរ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះម៉ូ រឹម(ស)ម្តាយឈ្មោះ ពូញ ហួត(រ)ជាតំណាងឱ្យប្រជាជនចំនួន៨៤គ្រួសារ ។

មានមេធាវីលោកណបផ ។

និងចុងចម្លើយឈ្មោះសលដ (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស ជាតិខ្មែរ របររកសុីធ្វើស្រែ មានទីលំនៅ ភូមិស្វាយសរឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ ម៉ក សាលី(ស) ម្តាយឈ្មោះ យ៉ាន់ សឿន (ស) ។ តំណាងឱ្យប្រជាជនភូមិស្វាយសរ ។

មានមេធាវីលោក ............... ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារដីស្រែទំហំ១.៥០០ម x ៩០០ម ។

បានឃើញបណ្តឹងសាទុក្ខលេខ២៣១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះររ បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២១៩ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី១០-០៥-២០០២ របស់ឈ្មោះរ រ ជាតំណាងឱ្យប្រជាពលរដ្ឋចំនួន ៨៤ គ្រួសារប្តឹងសុំទាមទារដីស្រែទំហំ១.៥០០មx៩០០ម ពីប្រជាជនភូមិស្វាយសរ ដោយសំអាងហេតុថា ប្រជាជន ភូមិអូររបស់ខ្លួនបាននឹងកំពុងធ្វើស្រែលើដីនេះចាប់តាំងពីឆ្នាំ១៩៩២ រហូតមកដល់បច្ចុប្បន្ននេះ និងមានលិខិតកាន់កាប់ដីពីលោកមេឃុំឆ្នាំ១៩៩២ និងលិខិតកាន់កាប់ដីមួយទៀតក្នុងឆ្នាំ ១៩៩៦ ។ ស្រាប់តែដល់ឆ្នាំ២០០១-២០០២ នេះប្រជាជនភូមិស្វាយសរដែលដឹកនាំដោយលោកសា លិញដឿម បានបំផុសឱ្យប្រជាជនមក ភ្ជួរយកដីស្រែដែល ជាកម្មសិទ្ធិរបស់ប្រជាជនភូមិអូរ ដោយសំអាងហេតុថា ជាដីកេរ្តិ៍តំណែលរបស់ខ្លួនតាំងពីសង្គមរាស្ត្រនិយមមកម្ល៉េះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៥២(ក) ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការខេត្ត បន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០១-០៥-២០០២រ រ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០៤-០៦-២០០២ របស់ប្រជាជនភូមិអូរមកឱ្យឈ្មោះរ រ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០១-០៧-២០០២ របស់ប្រជានភូមិស្វាយសរមកឱ្យឈ្មោះសា លិញដឿម ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-ប្រគល់ដីទំនាស់ទំហំ១.៥០០ម៉ែត្រx៩០០ម៉ែត្រ ស្ថិតនៅភូមិអូរ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្ត បន្ទាយមានជ័យ ឱ្យប្រជាជនភូមិអូរចំនួន៨៤គ្រួសារ ដែលមានឈ្មោះរ រ ជាតំណាងកាន់កាប់បង្កបង្កើនផល និងប្រើប្រាស់ជាកម្មសិទ្ធិកាលណាសាលក្រមចូលជាស្ថាពរ ។

៥-កាត់យកប្រាក់ប្រដាប់ក្តីចំនួន៧,០០០៛ ដែលដើមចោទបានបង់ទុករួចហើយគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្មឹង១.៨០០០៛សោហ៊ុយកិច្ចការស៊ើបអង្កេត៥.០០០៛ និងរង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ ។ កាលបើសាលក្រមនេះចូលជាស្ថាពរបង្គាប់ឱ្យចុងចម្លើយ គឺ ប្រជាជនភូមិស្វាយសរចំនួន១៤២គ្រួសារដែលមានឈ្មោះ សា លិញដឿម ជាតំណាងរួមគ្នាបង់ប្រាក់នេះទៅដើមចោទវិញ និងបង្គាប់ឱ្យចុងចម្លើយរួម គ្នាបង់ពន្ធសមាមាត្រមួយភាគរយលើដីទំនាស់នេះដែលជាប្រយោជន៍ថវិការដ្ឋ៨០% និងជាប្រយោជន៍ដល់ក្រឡាបញ្ជីកាន់ហិបប្រាក់២០% ។

សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៥៥ ចុះថ្ងៃទី០៦ ខែសីហាឆ្នាំ២០០២ របស់ឈ្មោះសា លីញដឿម

បានប្ដឹងមិនសុខចិត្ត នឹងសាលក្រមរបស់តុលាការ ខេត្តបន្ទាយមានជ័យ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការបៀបលេខ១២(គ) ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-បង្គាប់ឱ្យអាជ្ញាធរជំនាញគូសប្លង់ពីទំហំដីព្រៃ និងដីបង្កបង្កើនផលជាក់ស្ដែងរបស់គូភាគី នីមួយៗដោយមានការចូលរួមរវាងភាគីទំនាស់ជាតំណាង ។

២-រាយការណ៍ពីទំហំដីបង្កបង្កើនផលរបស់ភូមិនីមួយៗក្រៅពីដីទំនាស់ ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥៨(គ) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះសា លិញជឿម តំណាងឱ្យប្រជាជនភូមិស្វាយសរ ចុះថ្ងៃទី០៦-០៨-២០០២ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៥២(ក) ចុះថ្ងៃទី១៨-០៧-២០០២ របស់តួលាការខេត្តបន្ទាយមានជ័យ ចោលជាអសារបង់ ។

៣-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី០១-០៥-២០០២ របស់ដើមចោទឈ្មោះរ តំណាងឱ្យប្រជាជនភូមិអូរ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

៤-ដីទំនាស់ដែលមានទំហំតាមគំនូសប្លង់ទីតាំងដីទំនាស់លេខ១០៨/០៥ ជនសស.បជ/សជក ចុះថ្ងៃទី០៥-០៥-២០០៥ ត្រូវបែងចែកជាពីរឲ្យភាគីម្ខាងៗកាន់កាប់តាមច្បាប់ តាមគំនូសគូសបន្ថែមដោយតុលាការមានចំណុចA និងB ជាបន្ទាត់ពុះគឺៈ

-ទំហំABCDEFGA ដែលមានបន្ទាត់ BC =៥០០ម និងបន្ទាត់ GA=៥០០ម ។

ក/-ផ្នែកខាងកើតប្រគល់ឱ្យប្រជាជនភូមិអូរ ។

ខ/-ផ្នែកខាងលិចដីទំនាស់សល់ពីចំណុចខាងលើ ប្រគល់ឱ្យប្រជាជនភូមិស្វាយសរ សំណូមពរលើសពីនេះ បដិសេធចោល ។

៥-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ គឺ ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ និងលើអាជ្ញាធរតុលាការ៥០០០៛ និងបង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ១% លើចំណែកដីទំនាស់ពាក់កណ្ដាល ដែលបានជាប្រយោជន៍ថវិការដ្ឋ៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៦-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩-០៦-២០០៥ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥-០៦-២០០៥ ចំពោះមុខគូភាគី បើផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៣១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះរ បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណារបស់ឈ្មោះរ តំណាងឱ្យប្រជាជន៨៤ គ្រួសារ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៥ ។

បានឃើញសារណាឆ្លើយតបរបស់ឈ្មោះមូលឃឿន,ទន់ល្មឿង តំណាងឱ្យប្រជាជន១៤២គ្រួសារ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៥ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា

បណ្តឹងសាទុក្ខរបស់ឈ្មោះរឹមរ៉ងស្ថិតក្នុងកំណត់ច្បាប់គប្បីលើកយកមកជំនុំជំរះបាន ។

សាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សា ជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់ ។

លោករ បាត្លើយថា ខ្លួនប្តឹងសាទុក្ខមកនេះគឺ សុំឱ្យតុលាការកំពូល សម្រេចសេចក្តីដូចសាលក្រមរបស់ តុលាការខេត្តបន្ទាយមានជ័យវិញ ដីទំនាស់នេះសព្វថ្ងៃកំពុងបង្កបង្កើនផលពាក់កណ្តាលម្នាក់។

មេភូមិអូរ បានធ្វើយថា ដីទំនាស់នេះគឺជាដីរបស់ប្រជាជនភូមិរបស់ខ្លួនទេ ហើយប្រជាជនស្វាយសរមក រំលោភយកដីរបស់ប្រជាជនភូមិខ្លួនប្រាកដមែន ។

សំណូមពរសុំឱ្យតុលាការកំពូលជួយសំរួលដីនេះជូនប្រជាជនខ្លួនផង ។

លោក មូល ឃឿន បានឆ្លើយថា ៖ ពាក្យដែលគាត់បានលើកឡើងថាចូលមកកាន់កាប់តាំពីឆ្នាំ៩២មកនោះ មិនត្រឹមត្រូវទេព្រោះដីនេះជាតំបន់អសន្តិសុខគ្មានអ្នកណាមកកាន់កាប់មុនឬក្រោយទេគឺចូលមកកាន់កាប់តំណាលគ្នា

**សំណូមពរ** សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

លោក ទន់ ឈឿង បានឆ្លើយថា : សុំឱ្យតុលាការបញ្ចប់រឿងក្តីនេះត្រឹមនេះដោយតម្កល់សាលដីការបស់ សាលាឧទ្ធរណ៍ទុកជាបានតាវិញ ។

មេធាវីលោកណបផ ការពារឱ្យប្រជាជនភូមិអូរ បានធ្វើសេចក្តីសន្និដ្ឋានថា៖

ខ្លួនសុំលើកពីអង្គហេតុត្រួសៗដើម្បីជូនជ្រាបជាមុន ដីនេះមុនជាតំបន់អស្ថិសុខហើយជាកន្លែងដែលសមរភូមិ ក្តៅមិនដែលមានប្រជាជនណាមកបង្កបង្កើនផលលើដីនេះឡើយ ទើបនៅពេលបញ្ចប់សង្គ្រាមរដ្ឋអំណាចប្រជាជនភូមិ អូរ បង្កបង្កើនផលលើដីនេះ ស្រាប់តែនៅឆ្នាំ២០០១-២០០២ មានប្រជា

ជនភូមិស្វាយសរចូលមករំលោភកាន់កាប់ដី នេះដែលជាដីរបស់ភូមិអូរ ។ ដីទំនាស់នេះប្រជាជនភូមិអូរ បានកាប់ឆ្ការស្អាតបាតហើយ ទើបប្រជាជនភូមិស្វាយសរ មកបំពានយកតែម្តង នៅតុលាការខេត្តបន្ទាយមានជ័យបានសម្រេចប្រគល់ឱ្យប្រជាជនភូមិអូរជាកម្មសិទ្ធិតាមច្បាប់ហើយ ។ សាលាឧទ្ធរណ៍បានសម្រេចចែកដីនេះជាពីរដែលមិនបានយកច្បាប់អ្វីមកធ្វើជាសំអាងឡើយ គឺយកប្លង់ដីមកពុះបំបែកជាពីរតែម្តង ដែលមានលក្ខណៈខុសពីភាពជាក់ស្តែងនៃប្លង់ដីនេះស្រឡាស់ ។

តាមច្បាប់ការកាន់កាប់របស់ប្រជាជនភូមិអូរ គឺមានលក្ខណៈពិសេសព្រោះគាត់មានលទ្ធកម្មពិសេស ដែលបញ្ជាក់ថា ដីនេះជារបស់ប្រជាជនភូមិអូរ ប្រាកដណាស់ ។ ចំណែកឯប្រជាជនភូមិស្វាយសរទើបចូលមកធ្វើការ បង្កបង្កើនផលនៅពេលក្រោយ តុលាការកំពូល បានចេញលិខិតឱ្យហាមឃាត់ ដូច្នេះប្រជាជនភូមិស្វាយសរ បានបំពានលើច្បាប់ទាំងស្រុង ។

**សមណ្ឌមពរៈ** សុំបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

មេធាវីអ្នកស្រី ស៊ិន សុវ៉ែន ការពារឱ្យប្រជាជនភូមិស្វាយសរ បានធ្វើសេចក្តីសន្និដ្ឋានថាៈ

តាមការដែលខ្លួនបានចុះទៅស៊ើបសួរ និងអង្កេតដល់ទីកន្លែងផ្ទាល់ឃើញថានៅឆ្នាំ១៩៧៩-១៩៩២ ដីនេះមិនមានអ្នកណាចូលមកបង្កបង្កើនផលលើដីនេះឡើយ ព្រោះតំបន់នោះជាតំបន់អស្ថិសុខមិនមានជនណាចូលមកបង្កបង្កើផលបានឡើយ ។

ទើបតែមានសន្តិសុខបានប្រជាជននាំគ្នាចុះបង្កបង្កើនផលលើដីនេះតំណាលគ្នា គឺមិនអាចមានអ្នកណាធ្វើមុនធ្វើក្រោយឡើយ ហើយជាក់ស្តែងសព្វថ្ងៃប្រជាជនទាំងពីរភូមិនេះកំពុងតែបង្កបង្កើផលលើដីនេះពាក់កណ្តាម្នាក់ តែភូមិអូរបានដីធំជាងភូមិស្វាយសរ។ នៅពេលដែលប្រជាជនភូមិស្វាយសរភ្ជួរដីសាបព្រោះស្រូវហើយ ប្រជាជនភូមិអូរ បានមកភ្ជួររាស់ពីលើបណ្តាលឱ្យខូចខាតផលដំណាំអស់ ឯកឧត្តមកាលពីមុនប្រជាជនភូមិអូរ និងភូមិស្វាយសរ ជាភូមិតែមួយទេ ដោយមានកំណើនប្រជាជនច្រើនទើបគេបំបែកជាពីរភូមិ ដូច្នេះបានជាដីនេះត្រូវបែកជាពីរតាមរបបប្រជាជន ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអោយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៣១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះររ ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ពុំមានភស្តុតាងដែលបញ្ជាក់ច្បាស់ថា ប្រជាជនភូមិអូរ បានចូលមកកាន់កាប់ជាក់ស្តែងលើដី ទំនាស់តាំងតែពីឆ្នាំ១៩៩២ ក្រោយពីលោករឿង ចំ បានប្រគល់ឱ្យតាមលិខិតចុះថ្ងៃទី០៩-០៩-១៩៩២ នោះឡើយ ដោយហេតុថាលោករឿង ចំ បានបញ្ជាក់តាមលិខិតចុះថ្ងៃទី២៦ ខែមករា ឆ្នាំ ២០០៤ ថា ថ្វីត្បិតតែលោកជាអ្នកអនុញ្ញាតឱ្យអ្នកភូមិអូមែនតែលោកមិនបានដឹងពីការកាន់កាប់ជាក់ស្តែងនោះទេ និងម្យ៉ាងទៀតទាំងលោករឿងចំ ក្តីលោក អាង គេទ ជាមេភូមិផ្តាំក្នុងឆ្នាំ២០០១ ក្តី ក៏ដូចជាលោក ផេង ប៉ោត ដែលជាមេភូមិផ្តាំក្រោយដែរបានបញ្ជាក់ក្នុងន័យប្រហាក់ប្រហែលគ្នាថា ប្រជាជនទាំងពីរភូមិចាប់ផ្តើមចូលកាន់កាប់ដីទំនាស់នេះនៅឆ្នាំ២០០១ដូចគ្នាទើបកើតមានទំនាស់ ដូចនេះការដែលសាលាឧទ្ធរណ៍ លើកយក គោលការណ៍សមធម៌មកពីចារណា និងសម្រេចនោះជាការត្រឹមត្រូវហើយ ។

យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខ៥៨(គ) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ២៣១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះររ ទុកជា ត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៥៨(គ) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលដើមចោទបានបង់ គឺៈ

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវគាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគលល់ដីកាកោះចំនួន១៥០០០៛ សរុប១៩០០០៛ ។

បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រតាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៤-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៦ ។